**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

លេខ: ....៥៤៥១......ន.ទ.ក.

# សេចក្ដីជូនដំណឹង
# ស្ដីពី
# ភាពមិនប្រក្រតីនៃការផ្ញើសារខ្លីរបស់ប្រតិបត្តិករទូរស័ព្ទចល័ត ដែលធ្វើឱ្យមានការភាន់ច្រឡំដល់អ្នកប្រើប្រាស់

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) សូមជម្រាបជូនសាធារណជនជ្រាបថា ក្នុងពេលថ្មីៗនេះ តាមរយៈបណ្ដឹងតវ៉ាពីអ្នកប្រើប្រាស់ ន.ទ.ក. បានរកឃើញភាពមិនប្រក្រតីរបស់ប្រតិបត្តិករទូរស័ព្ទចល័តមួយចំនួន ពាក់ព័ន្ធនឹងការផ្ញើសារខ្លី (Short Message Service-SMS) ជូនដំណឹងទៅកាន់លេខទូរស័ព្ទរបស់អ្នកប្រើប្រាស់ ដែលបានធ្វើឱ្យមានការភាន់ច្រឡំដល់អ្នកប្រើប្រាស់ទាំងនោះ ដូចខាងក្រោម÷

១. ការតម្រូវ និង/ឬជំរុញឱ្យអ្នកប្រើប្រាស់បញ្ចូលទឹកប្រាក់ក្នុងគណនីគោល ដើម្បីអាចបន្តសុពលភាពគណនីគោលឬគម្រោងឬសេវាកម្មផ្សេងៗ ខណៈពេលដែលគណនីគោលឬគម្រោងឬសេវាកម្ម រួមទាំងទិន្នន័យអ៊ីនធឺណិត កំពុងមានសុពលភាពនៅឡើយ។

២. ការផ្ញើសារខ្លីទៅលេខទូរស័ព្ទរបស់អ្នកប្រើប្រាស់មានភាពយឺតយ៉ាវពាក់ព័ន្ធនឹងព័ត៌មានអំពីគម្រោងឬសេវាកម្មនានា និង/ឬរយៈពេលសុពលភាពនៃគម្រោងឬសេវាកម្ម បន្ទាប់ពីអ្នកប្រើប្រាស់បានបញ្ចូលទឹកប្រាក់ក្នុងគណនីគោល និង/ឬបានបន្តឡើងវិញដោយជោគជ័យនូវគម្រោងឬសេវាកម្ម។

៣. ការផ្ញើសារខ្លីបញ្ជាក់សុពលភាពឬលក្ខខណ្ឌនានានៃការប្រើប្រាស់គម្រោង និង/ឬសេវាកម្មណាមួយ ខណៈពេលដែលអ្នកប្រើប្រាស់ពុំធ្លាប់បានភ្ជាប់ការប្រើប្រាស់គម្រោងឬសេវាកម្មនោះពីមុនសោះឡើយ។

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការពង្រឹងការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ ព្រមទាំងចូលរួមការទប់ស្កាត់សកម្មភាពមិនប្រក្រតីពាក់ព័ន្ធនឹងការផ្ដល់សេវាទូរស័ព្ទចល័តនិងការផ្ញើសារខ្លីដែលមានខ្លឹមសារដូចខាងលើ ន.ទ.ក. សូមអំពាវនាវដល់អ្នកប្រើប្រាស់សេវាទូរស័ព្ទចល័តទាំងអស់ រាយការណ៍មក ន.ទ.ក. តាមរយៈលេខទូរស័ព្ទ ៦៧៨៩ រៀងរាល់ម៉ោងធ្វើការ ឬផ្ញើសារមកកាន់អ៊ីម៉ែល info@trc.gov.kh ឬតាមរយៈហ្វេសប៊ុក “**និយ័តករទូរគមនាគមន៍កម្ពុជា - Telecommunication Regulator of Cambodia**”។

ន.ទ.ក. នឹងបន្តតាមដាននិងចាត់វិធានការយ៉ាងតឹងរ៉ឹងបំផុត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ចំពោះប្រតិបត្តិករទូរស័ព្ទចល័តណា ដែលបានប្រព្រឹត្តខុស ដោយគ្មានការរើសអើង ដោយសមភាព និងដោយពុំមានការលើកលែងឡើយ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៥ កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥